ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ ៧១៦ ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ [illegible] ឆ្នាំ២០១៤

# ប្រកាស
## ស្តីពី
## ការប្រើប្រាស់សៀវភៅជំនាញទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍
## និងជាប្រធានគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍

- *បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*
- *បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា*
- *បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី*
- *បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍*
- *បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីទេសចរណ៍*
- *បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍*
- *បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារនិងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាននៃក្រសួងទេសចរណ៍*
- *បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍*
- *បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៣៤ សសរ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការតែងតាំងសមាសភាពរបស់គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍*
- *យោងតាមស្មារតីនៃកិច្ចប្រជុំគណៈកម្មការជាតិអ្នកជំនាញទេសចរណ៍ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤ និងយោងតាមតម្រូវការចាំបាច់នៃការងាររបស់គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍*

## សម្រេច

**ប្រការ ១.**

ប្រកាសនេះមានគោលបំណងដាក់ឱ្យប្រើប្រាស់សៀវភៅជំនាញទេសចរណ៍ ដូចមានក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ដើម្បីលើកកម្ពស់ និងអភិវឌ្ឍជំនាញទេសចរណ៍ ប្រកបដោយប្រសិទ្ធិភាព និងគុណភាពខ្ពស់។

សៀវភៅជំនាញទេសចរណ៍ គឺជាសក្ខីបណ្ណដែលបញ្ជាក់អំពីសមាសធាតុនៃគុណវុឌ្ឍិរបស់អ្នកជំនាញទេសចរណ៍។

**ប្រការ ២.**_

សៀវភៅជំនាញទេសចរណ៍ត្រូវបានដាក់ឱ្យប្រើប្រាស់ដល់អ្នកជំនាញទេសចរណ៍ និយោជកនៃវិស័យទេសចរណ៍ អង្គភាព ឬកម្មវិធីបណ្តុះបណ្តាលជំនាញទេសចរណ៍។

កំណត់ត្រាក្នុងសៀវភៅជំនាញទេសចរណ៍ អាចយកទៅប្រើប្រាស់ជាភស្តុតាងនៃការវាយតម្លៃសមត្ថភាព ការជ្រើសរើសបុគ្គលិក ការផ្តល់រង្វាន់ ឬការធ្វើផែនការអភិវឌ្ឍជំនាញ។

**ប្រការ ៣.**_

សៀវភៅជំនាញទេសចរណ៍នេះ ប្រើប្រាស់សម្រាប់កត់ត្រាគុណសម្បត្តិចំនួនបីសំខាន់ៗ របស់អ្នកជំនាញទេសចរណ៍ដូចជា៖

(១) **ការចូលរួមវគ្គបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈរយៈពេលខ្លី មធ្យម និងវែង ទាំងក្នុង និងក្រៅប្រទេសស្តីពីជំនាញជាក់លាក់ណាមួយ កម្មសិក្សា ព្រមទាំងវគ្គបណ្តុះបណ្តាលដែលរៀបចំដោយផ្ទាល់នៅក្នុងស្ថាប័ន។

(២) **លិខិតសរសើរ ឬពានរង្វាន់ផ្សេងៗ**

អ្នកជំនាញទេសចរណ៍ ឬស្ថាប័នអាចស្នើសុំឲ្យមានការកត់ត្រាអំពី លិខិតសរសើរ ស្នាដៃ ឬពានរង្វាន់ផ្សេងៗដែលខ្លួនទទួលបាន។ លិខិតសរសើរ ស្នាដៃ ឬពានរង្វាន់គឺជាផ្នែកមួយនៃសក្ខីបណ្ណ ដែលបញ្ជាក់អំពីសមត្ថភាពអ្នកជំនាញ ហើយដែលនឹងអាចត្រូវបានប្រើប្រាស់សម្រាប់ធ្វើការវាយតម្លៃសមត្ថភាពផងដែរ។

(៣) **បទពិសោធន៍ការងារ**

បទពិសោធន៍ការងារ ដែលអ្នកជំនាញទេសចរណ៍បានទទួលនៅក្នុងអាជីពការងាររបស់ខ្លួន អាចស្នើសុំការបញ្ជាក់ ឬកត់ត្រាក្នុងសៀវភៅជំនាញទេសចរណ៍។

**ប្រការ ៤.**_

ដើម្បីទទួលបានការកត់ត្រារាល់គុណសម្បត្តិដូចមានចែងក្នុង ប្រការ ៣ សាម៉ីខ្លួន ឬអង្គភាពរបស់ខ្លួនត្រូវធ្វើការស្នើសុំតាមរយៈលិខិតទៅប្រធានគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ (គ.ជ.អ.ទ.) ដោយភ្ជាប់នូវឯកសារយោង ឬសក្ខីបណ្ណផ្សេងៗ។

បន្ទាប់ពីបានទទួលការឯកភាពពីប្រធាន គ.ជ.អ.ទ. លេខាធិការដ្ឋានអាចចុះកត់ត្រារាល់គុណសម្បត្តិដែលទទួលបានការឯកភាព ក្នុងសៀវភៅជំនាញទេសចរណ៍ ដោយមានចុះហត្ថលេខាទទួលស្គាល់ដោយប្រធានលេខាធិការដ្ឋាន គ.ជ.អ.ទ. ។

លេខាធិការដ្ឋាន គ.ជ.អ.ទ. អាចបញ្ចូលរាល់ទិន្នន័យអំពីការកត់ត្រាទាំងនេះក្នុងប្រព័ន្ធព័ត៌មានវិទ្យារបស់ខ្លួន។

**ប្រការ ៥.**

រាល់ទិន្នន័យ ដែលបានកត់ត្រានៅក្នុងសៀវភៅជំនាញទេសចរណ៍នេះមានសុពលភាព ដរាបណាមានការទទួលស្គាល់ពី គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍។

**ប្រការ ៦.**

គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ប្រើប្រាស់សៀវភៅនេះដើម្បីជាសក្ខីបណ្ណបញ្ជាក់សមត្ថភាពក្នុងដំណើរការវាយតម្លៃអ្នកជំនាញទេសចរណ៍អាស៊ាន។

**ប្រការ ៧.**

អ្នកជំនាញទេសចរណ៍ និយោជក អង្គភាព ឬកម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍នៅព្រះរាជាណាចក្រកម្ពុជា ត្រូវប្រើប្រាស់សៀវភៅជំនាញទេសចរណ៍ ដើម្បីចូលរួមលើកកម្ពស់ និងអភិវឌ្ឍជំនាញទេសចរណ៍ ព្រមទាំងផ្តល់ជាភស្តុតាងសម្រាប់ធ្វើការវាយតម្លៃអ្នកជំនាញទេសចរណ៍កម្ពុជា និងអាស៊ាន។

**ប្រការ ៨.**

សៀវភៅជំនាញទេសចរណ៍ អាចនឹងត្រូវបានធ្វើបច្ចុប្បន្នភាពតាមតម្រូវការចាំបាច់។

**ប្រការ ៩.**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១០.**

សមាជិក គ.ជ.អ.ទ. រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកទេសចរណ៍ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងទេសចរណ៍ គ្រប់ប្រធាននាយកដ្ឋាន ប្រធានក្រុមអ្នកច្បាប់នៃក្រសួងទេសចរណ៍ លេខាធិការដ្ឋាន គ.ជ.អ.ទ. ប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍**

**ប្រធាន**

**ថោង ខុន**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

***កន្លែងទទួល៖***

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ